Maine Department of Education

## ការផ្លាស់ប្តូរនិយមន័យនៃជំនាញភាសាអង់គ្លេសរបស់រដ្ឋម៉េន៖ ការណែនាំសម្រាប់សិស្ស និងគ្រួសារ

ថ្មីៗនេះក្រសួងអប់រំរដ្ឋម៉េនបានប្រកាសថាសិស្សដែលទទួលបានពិន្ទុ 4.5 ឬខ្ពស់ជាងនេះលើតេស្ត ACCESS សម្រាប់ ELLs នឹងលែងក្លាយជាអ្នកសិក្សាភាសាអង់គ្លេស (ELs) ទៀតហើយ។ នេះគឺជាការផ្លាស់ប្តូរ*ពីឆ្នាំមុនៗ ហើយក្រសួងចង់ឱ្យសិស្ស និងក្រុមគ្រួសាររបស់ពួកគេដឹងអំពីមូលហេតុដែលការសម្រេចចិត្តនេះត្រូវបានធ្វើឡើង។

ក្រោមច្បាប់សហព័ន្ធ រដ្ឋនីមួយៗសម្រេចចិត្តថាតើច្បាប់នេះនឹងកំណត់ជំនាញភាសាអង់គ្លេសយ៉ាងដូចម្តេច។ ម្យ៉ាងទៀតក្រសួងអប់រំរដ្ឋម៉េនបានសម្រេចកំណត់ពិន្ទុលើតេស្ត ACCESS សម្រាប់ ELLs ដែលសិស្ស ELs ត្រូវតែឈានដល់ការចេញផុតពីភាសាអង់គ្លេសជាកម្មវិធីភាសាទីពីរ (ESL)។ ពិន្ទុនេះគួរតែស្ថិតនៅកម្រិតត្រឹមត្រូវដើម្បីធានាថាសិស្សមានជំនាញភាសាអង់គ្លេសគ្រប់គ្រាន់ដើម្បីទទួលបានជោគជ័យក្នុងការសិក្សាដោយគ្មានការគាំទ្រ ESL។

កន្លងមក ម៉េនគឺជារដ្ឋតែមួយគត់ដែលសិស្ស ELs ត្រូវការពិន្ទុ 6.0 (ពិន្ទុអតិបរមានៃតេស្ត) ដើម្បីចាកចេញពីកម្មវិធី ESL។ បន្ទាប់មកនៅឆ្នាំ 2017 ប្រព័ន្ធពិន្ទុតេស្ត ACCESS សម្រាប់ ELLs បានផ្លាស់ប្តូរ ហើយវាកាន់តែលំបាកដើម្បីសម្រេចបានពិន្ទុ 6.0។ នៅពេលនោះ ម៉េនបានបន្ទាបការកំណត់ពិន្ទុ នៃជំនាញភាសាអង់គ្លេសរហូតដល់ 5.0 ដែលប្រហាក់ប្រហែលគ្នាក្នុងកម្រិតលំបាកធៀបនឹងពិន្ទុ 6.0។

ឆ្នាំនេះ ក្រសួងបានពិនិត្យយ៉ាងជិតដល់អំពីរបៀបដែលសិស្ស ELs អនុវត្តតាមការវាយតម្លៃសិក្សាដែលតម្រូវដោយរដ្ឋរបស់យើង (eMPowerME និង SAT) ជាមួយនឹងពិន្ទុខុសៗគ្នាលើតេស្ត ACCESS ។ តិចជាងពាក់កណ្តាលនៃសិស្សដែលទទួលបានពិន្ទុ 4.5 លើតេស្ត ACCESS បានបំពេញ ឬលើសពីការរំពឹងទុករបស់រដ្ឋចំពោះមុខវិជ្ជាអក្សរសាស្ត្រអង់គ្លេសលើការវាយតម្លៃសិក្សាដែលតម្រូវដោយរដ្ឋ ដែលមានភាពដូចគ្នានឹងរបៀបដែលសិស្សដែលមិនមែនជាសិស្ស EL បានអនុវត្ត។ នេះបង្ហាញឲ្យដឹងថានៅពេលសិស្សសម្រេចបានពិន្ទុ 4.5 លើតេស្ត ACCESS កម្រិតនៃភាសាអង់គ្លេសរបស់សិស្សលែងជាឧបសគ្គចំពោះការសិក្សាទៀតហើយ។

បន្ទាប់ពីសិស្ស EL ចេញពីកម្មវិធី ESL គ្រូបង្រៀនរបស់សិស្សតាមឃ្លាំមើលការសិក្សារបស់សិស្សនេះរយៈពេល 2 ឆ្នាំ ហើយប្រសិនបើសិស្សនេះនៅតែត្រូវការការគាំទ្រ ESL ត្រូវតែផ្តល់ការគាំទ្រផ្នែកនេះ។ (ចំណាំថាក្នុងករណីនេះសិស្សនឹងមិនធ្វើតេស្ត ACCESS ម្តងទៀតទេ។) ដូចគ្នានេះដែរ អតីតសិស្ស EL មួយចំនួនអាចបន្តត្រូវ
ការការគាំទ្រផ្នែកសិក្សាដើម្បីសម្រេចឲ្យបានសក្តានុពលពេញលេញរបស់ពួកគេហើយពួកគេគួរតែទទួលបានការគាំទ្រផ្នែកការសិក្សាតាមរយៈកម្មវិធី និងសេវាកម្មដូចគ្នាដែលសិស្សទាំងអស់អាចមានសិទ្ធិទទួលបាន (ដូចជា RtI ចំណាងជើង I និងការអប់រំពិសេស) ។

បើសិស្សរបស់អ្នកត្រូវបានកំណត់នាពេលថ្មីៗនេះថាជាសិស្ស EL ដែលទទួលបានពិន្ទុ 4.5 នៅលើតេស្ត WIDA Screener Online សិស្សរបស់អ្នកនឹងលែងជាសិស្ស EL ទៀតហើយ។ (ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើសិស្សបានធ្វើតេស្ត ACCESS រួចហើយ ហើយមិនបានពិន្ទុយ៉ាងហោចណាស់ 4.5 ទេ សិស្សនេះនឹងនៅតែជាសិស្ស EL រហូតដល់ទទួលបានពិន្ទុ 4.5 ឬខ្ពស់ជាងនេះនៅលើតេស្ត ACCESS។)

ដោយមិនគិតពីពិន្ទុរបស់សិស្សនៅលើតេស្ត ACCESS សិស្សទាំងអស់គួរតែត្រូវបានផ្តល់ឱកាសដើម្បីសិក្សាឯកសារសមស្របសម្រាប់កម្រិតរបស់ខ្លួន និងរៀនក្នុងថ្នាក់រៀន
ដែលមានការប្រកួតប្រជែងដែលនឹងរៀបចំសម្រាប់ពួកគេត្រៀមបញ្ចប់ការសិក្សាវិទ្យាល័យដើម្បីត្រៀមខ្លួនទៅរៀននៅមហាវិទ្យាល័យ ឬចាប់ផ្តើមចាប់អាជីព។ ការធ្វើជាសិស្ស EL មិនមែនជាឧបសគ្គមួយចំពោះការចូលរួមពេញលេញនៅក្នុងកម្មវិធីសិក្សា ឬក្រៅកម្មវិធីរបស់សាលាទេ។

ប្រសិនបើអ្នកមានចម្ងល់អំពីព័ត៌មានក្នុងលិខិតនេះ សូមទូរស័ព្ទមកខ្ញុំ ឬផ្ញើអ៊ីម៉ែលមកខ្ញុំ។

April Perkins

នាយកកម្មវិធី ESOL / កម្មវិធីពីរភាសា និងចំណងជើង III

23 State House Station
Augusta, ME 04333
ការិយាល័យ៖ (207)624-6627

ទូរស័ព្ទ៖ (207)441-9043

april.perkins@maine.gov